ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚◯៚៚៚

សាលាដំបូងខេត្តកំពង់ឆ្នាំង

៚◯៚

សាលក្រមព្រហ្មទណ្ឌលេខ: ១០ "ខ"

ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

សំណុំរឿងព្រហ្មទណ្ឌលេខ: ២២៧

ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧

# គ ា ម ន ា ម ប្រ ជ ា រ ា ស្ត្រ ខ្មែ រ

បើកសវនាការជាសាធារណៈនៅសាលសវនាការនាសាលាដំបូងខេត្តកំពង់ឆ្នាំង។

- បើកសវនាការ: នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ រសៀល។
- ប្រកាសសាលក្រម: នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨ រសៀល។

## ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ២២៧ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ:

ឈ្មោះ[redacted] **សំរឿន (តាអឿន)** ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិរលាំងទាក ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ទីលំនៅនៅ[redacted] កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" លែងលះទោសពីមុនគ្មាន។ (ឃុំខ្លួន ០៥.០៤.២០១៧)

ជាប់ចោទពីបទ: **ឃាតកម្ម** ប្រព្រឹត្តនៅភូមិក្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០.០៣.២០១៧។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

ដែលមានលោក [redacted]រុល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើ។ ២

Scanned by CamScanner

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ២៦៤ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត។

**ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ភឿង ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្ប[redacted] ស្រុកថ្មគោល ខេត្តបាត់ដំបង។

## ឯអង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីថ្ងៃទី ៣០.០៣.២០១៧ វេលាម៉ោង ០៨ និង ៣០នាទី នៅចំណុចផ្ទះឈ្មោះ [redacted] កែប ហៅ [redacted] ឆន ស្ថិតក្នុងភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានឈ្មោ[redacted] សំអូន ហៅតាអូន បានយកពូថៅកាប់លើឈ្មោះ [redacted] កែប ហៅ ឆន ជាបងថ្លៃ ដោយមានទំនាស់ពាក្យសម្តីជាមួយគ្នា ហើយត្រូវបានឈ្មោះ [redacted] ចាន់ថន ត្រូវជាបងស្រីបានទៅជួយឃាត់ បើយត្រូវបានឈ្មោះ[redacted] សំអូន កាប់ទៅលើឈ្មោះ [redacted] ចាន់ថន បណ្តាលឱ្យស្លាប់ទាំងពីរនាក់តែម្តង។

## នាពេលសវនាការ

**ក្រោយពីបាន:**

- ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សំអូន
- ស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] សារ៉ាត់
- ស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជឿង
- ស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted] ពៅ, [redacted] សុភី និង [redacted] ណូភា
- ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ស្តាប់ការកត់សម្គាល់ខ្លីៗ និងជាសំណូមពរចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## **សំអាងហេតុ**

១-តាមរបាយការណ៍ស៊ើបអង្កេតសន្និដ្ឋាន ដោយមន្រ្តីនគរបាលយុត្តិធម៌ មានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់បានថា ពិតជាមានការ ការសម្លាប់ កាលពីថ្ងៃទី ៣០.០៣.២០១៧ នៅត្រង់ចំណុចភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បង្ករឡើងដោយឈ្មោះ [redacted] សំអូន បានយកពូថៅកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] កែប និង [redacted] ចាន់ថន បណ្តាលឱ្យស្លាប់ ប្រាកដមែន។

២-ក្នុងអង្គសវនាការ :

-ជនជាប់ចោទឈ្មោះ [redacted] សំអូន បានឆ្លើយថា នៅថ្ងៃកើតហេតុនោះខ្លួនឱ្យបងថ្លៃជូនទៅវត្ត គាត់មិនជូនទៅទេ គាត់ឱ្យខ្លួនដើរទៅ តែខ្លួនមិនខឹងទេ ខ្លួនដើរទៅសិតសក់ ហើយក៏និយាយជាមួយគាត់តទល់គ្នា [illegible] ទៅពាក់អាវគាត់ទះថ្ងាសខ្លួនមួយដៃមិនឱ្យខ្លួនទៅ។ ថ្ងៃនោះនៅផ្ទះតែ៣នាក់ទេ បងខ្លួន ប្តីគាត់ ៧

Scanned by CamScanner

និងខ្លួន។ ខ្លួនឃើញពូថៅក៏កាប់គាត់តែម្តង បងស្រីខ្លួនចូលមកនិយាយថាកន្លែងនឹងមានដាក់កាមេរ៉ា និងថតសម្លេង រួចខ្លួនបានទាញពូថៅកាប់បងស្រីខ្លួនតែម្តង ពេលកាប់បងស្រីខ្លួនមិនមានបំណងទេ ពេលកាប់ហើយខ្លួនហត់ពេកក៏អង្គុយទៅ។ ខ្លួនយកពូថៅកាប់បងថ្លៃចំនួន ៧ពូថៅ ក្បាល៥ពូថៅ, ពោះ១ និងទ្រូង១ កាប់បងស្រីខ្លួនឈ្មោះ ចាន់ថន ត្រូវចំក្បាល គាត់ស្លាប់ទាំងពីរនាក់។ ខ្លួនដឹងថាកាប់នោះវាខុសច្បាប់។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]សារ៉ាត់ ថ្ងៃកើតហេតុនោះខ្លួនមិននៅកន្លែងកើតហេតុទេ។ កូនរបស់ខ្លួនស្លូតណាស់ មិនកាចអញ្ចឹងទេ គ្រាន់តែនិយាយច្រើន មានសភាពដូចពេលនេះ ០៣ឆ្នាំហើយ។ ខ្លួនដើររកគ្រូខ្មែរច្រើនកន្លែងហើយ ហើយខ្លួនបានទៅបើកថ្នាំនៅពេទ្យរុស្សីដែរ។ ខ្លួនចេញពីផ្ទះបានពីរថ្ងៃកូននៅបាត់ដំបងគេប្រាប់ថាកូនស្រីខ្លួន និងកូនប្រសារស្លាប់ហើយ ពេលខ្លួនទៅដល់ផ្ទះវាបាត់ពីផ្ទះទៅហើយ។ កូនខ្លួនធ្លាប់ជាប់ពន្ធនាគារ ០៣ឆ្នាំ ម្តងហើយ។ ពេទ្យរុស្សីថាវាសសៃប្រសាទកម្រិតធ្ងន់ មានលិខិតបញ្ជាក់ និងសៀវភៅបើកថ្នាំ។

-ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា នៅថ្ងៃទី ៣០.០៣.២០១៧ វេលាម៉ោង ១៣ និង៣០នាទី ខ្លួនកំពង់នៅផ្ទះឈ្មោះ [redacted] សម្បត្តិ បានទូរស័ព្ទមកខ្លួនថាបងថ្លៃខ្លួនឈ្មោះ [redacted] កែប ត្រូវគេសម្លាប់នៅផ្ទះប្រពន្ធចុងគាត់ ហើយខ្លួនបានតេទៅទាក់ទងសមត្ថកិច្ចនៅទីនោះគេប្រាប់ខ្លួនថា បងថ្លៃខ្លួន និងប្រពន្ធចុងគាត់ ត្រូវប្អូនបង្កើតប្រពន្ធចុងជាអ្នកសម្លាប់។ ខ្លួនបានទាក់ទងទៅប្រពន្ធដើមគាត់យកសពគាត់ទៅធ្វើបុណ្យនៅស្រុកកំណើត។

-សាក្សីឈ្មោះ [redacted]ណូភា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី ៣០.០៣.២០១៧ វេលាម៉ោង ៨និង៣០នាទី ខ្លួនកំពង់ធ្វើត្រីនៅក្រោមដើមស្វាយនៅផ្ទះ ស្រាប់តែឮ [redacted]ាន់ថន ហៅតូច ស្រែកថា អើមីអូន ខ្លួនក៏ងាកមើលឃើញគាត់នៅក្រោមដើមត្នោតក្បែរផ្ទះគាត់ ហើយរត់ចូលក្នុងផ្ទះគាត់វិញ ឮគាត់ស្រែកថាជួយប្តីខ្ញុំផង និងឃើញគាត់ចាប់ទាញប្អូនប្រុសគាត់ឈ្មោះ សំអូន ចេញមកមុខផ្ទះ ឃើញប្អូនគាត់មានកាន់ពូថៅនៅនឹងដៃ រួច មីងតូច ក៏រត់ចូលក្នុងផ្ទះហើយប្អូនគាត់ក៏រត់ស្ទុះទៅតាមក្រោយ ហើយបាត់សម្លេងឈឹង បានបន្តិចក្រោយមកក៏ឃើញប្អូនគាត់ចេញមកវិញដើរជុំវិញផ្ទះពុំឃើញមានកាន់អ្វីទេ រួចឃើញគាត់ដើរទៅពាងទឹកលាងសម្អាតខ្លួន រួចចូលក្នុងផ្ទះស្លៀកពាក់ខោអាវ ហើយដើរចេញទៅទិសខាងលិចបាត់។ បន្ទាប់មកខ្លួនបាននិយាយរឿងនេះប្រាប់យាយ ហើយគាត់នាំខ្លួនទៅផ្ទះមីងតូច ពេលទៅដល់ឃើញមីងតូច និងប្តីគាត់ត្រូវគេកាប់សម្លាប់ទាំងពីរនាក់ក្នុងផ្ទះ។

-តាមការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សុភី ឱ្យដឹងថា នៅថ្ងៃទី ៣០.០៣.២០១៧ វេលាម៉ោង ៨ និង ៣០នាទី ខ្លួនកំពុងអង្គុយលើគ្រែក្រោមដើមស្វាយនៅផ្ទះរបស់ខ្លួន បានឮសម្លេងស្រែកថា ជួយប្តីខ្ញុំផងៗ ហើយខ្លួនងាកមើលឃើញឈ្មោះ [redacted] ចាន់ថន (តូច) ចាប់ទាញប្អូនប្រុសគាត់ឈ្មោះ សំអូន ចេញមកក្រៅផ្ទះ និងស្រែកយំយ៉ាងខ្លាំង ហើយខ្លួនក៏ដើរចូលទៅក្នុងផ្ទះ មិនដឹងឈ្មោះគ្នារឿងអីទេព្រោះមិនចាប់អារម្មណ៍ បន្តិចក្រោយមកខ្លួនក៏បានដើរទៅប្រាប់ឈ្មោះ ធឿន និងឈ្មោះ ទូច រួចពួកគាត់នាំគ្នាដើរទៅមើលឃើញប្តីប្រពន្ធទាំងពីរនាក់ស្លាប់បាត់ទៅហើយ ហើយខ្លួនក៏រាយការណ៍ទៅមេភូមិ និងប៉ុស្តិ៍សមត្ថកិច្ចតែម្តង។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ពៅ កាលពីថ្ងៃទី ៣០.០៣.២០១៧ វេលាម៉ោងប្រហែល ៨ ៣០នាទី ខ្លួនកំពុងអង្គុយលេងផ្ទះមីងរបស់ខ្លួនឈ្មោះទូច នៅភូមិជាមួយគ្នាបានបន្តិចខ្លួនក៏ជិះម៉ូតូទៅផ្ទះបងខ្លួនឈ្មោះ ទិន នៅក្បែរនោះ ស្រាប់តែឃើញឈ្មោះ សំអូន ដែលជាប្អូនប្រុសរបស់ឈ្មោះ ចាន់ថន ដើរមកដល់ ២

ឃើញស្លៀកខោកីឡាមិនចាំពណ៌ និងពាក់អាវដៃខ្លីពណ៌ស បានសុំពឹងខ្លួនឱ្យឌុបជូនទៅផ្លូវជាតិលេខ៥ ម្តុំផ្សារត្រាច ខ្លួនក៏ព្រមពេលទៅដល់ សំអូន ក៏ចុះមិនដឹងទៅណាទេ រួចខ្លួនក៏ជិះម៉ូតូត្រឡប់មកផ្ទះបងស្រីខ្លួនវិញ។ ប្រហែលមួយម៉ោងក្រោយមកស្រាប់តែឮអ្នកភូមិភ្លើលនិយាយថា ចាន់ថន និងប្តីរបស់គាត់ត្រូវគេកាប់សម្លាប់។

*តាមចម្លើយសារភាពរបស់ជនជាប់ចោទ, អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាបានយកពូថៅកាប់ទៅលើបងថ្លៃ និងបងស្រីបង្កើតបណ្តាលឱ្យស្លាប់នៅនឹងកន្លែងប្រាកដមែន។ ទង្វើរបស់ជនជាប់ចោទ ត្រូវបានច្បាប់បញ្ញាតិថាជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។*

-លោកតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ : ក្រោយពីបានស្តាប់ការសួរដេញដោលក្នុងអង្គសវនាការឃើញថា កាលពីថ្ងៃទី ៣០.០៣.២០១៧ ពិតជាមានករណីឃាតកម្ម ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted]សំអូន។ ជនជាប់ចោទបានសារភាពថាពិតជាបានកាប់ទៅលើបងថ្លៃឈ្មោះ [redacted] កែប និងបងស្រីបង្កើតឈ្មោះ [redacted]ចាន់ថន បណ្តាលឱ្យស្លាប់ពិតមែន។ ដូច្នេះ តំណាងអយ្យការសុំតម្កល់បទចោទ និងសុំឱ្យដាក់ក្រមផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារ : តាមរយៈអង្គសវនាការឃើញថា កូនក្តីរបស់ខ្លួនមានស្មារតីច្របូកច្របល់ និយាយយកជាការមិនបាន ហើយម្តាយបានអះអាងថាធ្លាប់យកទៅពេទ្យរុស្ស៊ីព្យាបាល។ ដូច្នេះសុំចៅក្រមចាត់របៀប និងធ្វើកោសល្យវិច្ច័យទៅលើស្មារតីរបស់កូនក្តីខ្លួនមុននឹងសម្រេចសេចក្តី។

*ការស្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលស្នើសុំឱ្យតុលាការចាត់របៀបដើម្បីឱ្យអ្នកជំនាញធ្វើកោសល្យវិច្ច័យទៅលើស្មារតីរបស់ជនជាប់ចោទនោះ តុលាការមិនឯកភាពនោះទេព្រោះថា ក្នុងពេលសវនាការជនជាប់ចោទអាចឆ្លើយបាននូវរាល់សំណួររបស់ក្រុមប្រឹក្សាជំនុំជម្រះ តំណាងអយ្យការ ក៏ដូចជាមេធាវី ហើយចម្លើយនោះទៀតសោតមិនមានចម្លើយណាមួយដែលបញ្ជាក់ពីវិបលស្មារតីរបស់ជនជាប់ចោទ ដើម្បីឈានទៅដល់ការធ្វើកោសល្យវិច្ច័យនោះទេ ដោយជនជាប់ចោទបានឆ្លើយនូវរាល់សកម្មភាពរបស់ខ្លួន ហើយជនជាប់ចោទក៏បានឆ្លើយផងដែរថា ខ្លួនដឹងថាសម្លាប់មនុស្សគឺខុសច្បាប់។*

៣-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តសកម្មភាពខាងលើ ដោយចេតនាយល់ដឹងគ្រប់គ្រាន់។

៣.១-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted]សំអូន ពីបទ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០.០៣.២០១៧។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

៣.២-គប្បីប្រកាសទណ្ឌកម្មលើជនជាប់ចោទ ចំនួន ១០ឆ្នាំ (ដប់ឆ្នាំ) ដោយពិចារណាដល់ភាពធ្ងន់ស្រាលនៃសកម្មភាពល្មើស ផលប៉ះពាល់ និងព្យសនកម្ម ដែលកើតចេញពីអំពើល្មើស និងស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ដូចខាងក្រោម:

-អំពើល្មើសរបស់ជនជាប់ចោទ បណ្តាលឱ្យជនរងគ្រោះដែលជាបងបង្កើត និងបងថ្លៃបាត់បង់ជីវិត ហើយសកម្មភាពជនជាប់ចោទប្រព្រឹត្តបទដោយភាពក្លាហាន ដោយឃោរឃៅ អមុស្សធម៌ តែជនជាប់ចោទ ..សារភាពនូវរាល់ទង្វើរបស់ខ្លួន មិនបានបង្កផលវិបាកដល់តុលាការក្នុងការស្វែងរកការពិតនោះទេ។។ ...នេះហើយ ដែលនាំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទ ដូចក្នុងចំណុច ៣.២ ខាងលើ ។

៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធឿន មិនបានទាមទារសំណងជម្ងឺចិត្តពីជនជាប់ចោទនោះទេ ដូច្នេះ តុលាការមិនពិចារណាដើម្បីសម្រេចពីបញ្ហាសំណងរដ្ឋប្បវេណីទេ។

## សេចក្តីសម្រេច

១-*ផ្ដន្ទាទោសជនជាប់ចោទ :* ឈ្មោះ [redacted] **សំអូន (តាអូន)** ភេទប្រុស អាយុ ៣៣ឆ្នាំ **ដាក់ពន្ធនាគារកំណត់ចំនួន ១០ឆ្នាំ (ដប់ឆ្នាំ)** ពីបទ **ឃាតកម្ម**

ប្រព្រឹត្តនៅភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០.០៣. ២០១៧។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។ ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
កំពង់ឆ្នាំង, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨
**ក្រឡាបញ្ជី**
[redacted]

បានឃើញ និងឯកភាព
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

Scanned by CamScanner